# ខ្លឹមសារសង្ខេបអញ្ញត្រកម្មបឋមស្ដីពីការរលត់បណ្ដឹងអាជ្ញា E47 ១៤ ខែកុម្ភៈ ឆ្នាំ២០១១

**ពាក្យគន្លឹះ៖** គោលការណ៍មិនប្រតិសកម្មនៃច្បាប់, អាជ្ញាយុកាលចោទប្រកាន់នៃបទល្មើស

១. នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (អង្គជំនុំជម្រះ)នៃអង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា (អវតក) និងក្នុងដំណាក់កាលដំបូងនៃសវនាការ លោក ខៀវ សំផន (លោកសំផន) បានដាក់ញត្តិជំទាស់ជាបឋម (preliminary objection: OP) ពាក់ព័ន្ធអាជ្ញាយុកាលនៃការចោទប្រកាន់បទល្មើសជាតិ ដូចជាទារុណកម្ម ក្រោមច្បាប់ព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦។

២. គាត់អះអាងថា អាជ្ញាយុកាលចោទប្រកាន់សម្រាប់បទល្មើសទារុណកម្ម មានរយៈពេល ១០ឆ្នាំ ហើយពេលវេលានិងបញ្ចប់ ប្រសិនបើមិនមានកិច្ចស៊ើបអង្កេតឬចោទប្រកាន់ណាមួយទេ។ ច្បាប់ស្ដីពីការបង្កើតឲ្យ **អវតក** បានពន្យាអាជ្ញាយុកាលរហូតដល់៣០ឆ្នាំ (កថាខ័ណ្ឌទី៤ និង៧)។ លោក**សំផន** យោងដល់យោបល់របស់ចៅក្រមអន្តរជាតិ *«មិនមានតម្រូវការឲ្យបកស្រាយច្បាប់នោះទេ ប្រសិនច្បាប់នោះចែងច្បាស់លាស់ និងថាបទបញ្ញត្តិទាក់ទងនឹងបទល្មើសនានា ត្រូវធ្វើការបកស្រាយយ៉ាងតឹងរឹង»* ហើយបានអះអាងថា ច្បាប់ចែងថារយៈពេលចោទប្រកាន់គឺ១០ឆ្នាំ ដូចនេះ គិតពី១៩៧៩ រយៈពេលត្រូវបានបញ្ចប់ក្នុងឆ្នាំ១៩៨៩។ ការធ្វើច្បាប់ពន្យាអាជ្ញាយុកាលដែលចប់ទៅហើយ មិនត្រឹមត្រូវតាមច្បាប់ទេ (កថាខ័ណ្ឌទី១៨ និង២២)។ ការពន្យានេះនាំឲ្យប៉ះដល់គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ (equality before law) គោលការណ៍ជាក់លាក់នៃច្បាប់ (legal certainty) និងមិនប្រតិសកម្ម (non-retroaction)។ សម្រាប់គោលការណ៍ទី១ច្បាប់ធ្វើដូចនេះ អនុវត្តមិនទូទៅនិងអនុវត្តចំពោះលើតែជនក្នុងសមត្ថកិច្ចរបស់ **អវតក** ដែលមាន**លោកសំផន** ផងដែរ។ ទីពីរ ការធ្វើច្បាប់ដូចនេះមិនបង្ហាញនូវភាពប្រាកដប្រជានៃច្បាប់ និងមិនស្របគោលការណ៍មិនប្រតិសកម្ម។

៣. ផ្អែកលើមូលដ្ឋានខាងលើលោក **សំផន** ស្នើឲ្យអង្គជំនុំជម្រះ រកឃើញថាពេលវេលាសម្រាប់ការចោទប្រកាន់បទល្មើសក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានបិទបញ្ចប់ (កថាខណ្ឌទី២៥)។

**កំណត់សំគាល់**៖ ក. បញ្ហាអាជ្ញាយុកាលនៃបទល្មើស បានលើកឡើងមកផងដែរក្នុងសំណុំរឿង ០០១ដែលមាន ឌុច ជាជនត្រូវចោទនាពេលនោះ។ ខ. ក្នុងញត្តិនេះ លោក **សំផន** បានយោងនិងគាំទ្រនូវអំណះអំណាងរបស់ជនត្រូវចោទដទៃទៀត ដូចជា ឌុច និងលោក អៀង សារី អាស្រ័យហេតុនេះ យើងពិបាកយល់ស៊ីជម្រៅនូវអំណះអំណាង។ ជាក់ស្ដែង ការអះអាងអំពីភាពផ្ទុយនឹងគោលការណ៍មិនប្រតិសកម្ម ខណៈដែលលោក **សំផន** ទទួលបានប្រយោជន៍នៃទោសស្រាលជាងទោសប្រហារជីវិត ទោស

ប្រហារជីវិត (ច្បាប់ស្តីពី**អវតក** បានលុបចោលទោសនេះ បន្ទាប់ពីក្រុមប្រឹក្សាធម្មនុញ្ញ បានអះអាង ថា ការដាក់ទោសប្រហារជីវិតផ្ទុយនឹងច្បាប់ធម្មនុញ្ញមាត្រា៣២ដែលចែងលុបទោសប្រហារជីវិត)។ **គ.** ក្រៅពីស្នើឲ្យមិនចោទប្រកាន់បទល្មើសជាតិ លោក សំផន បានស្នើឲ្យ អង្គជំនុំជម្រះពិចារណាញត្តិនេះ មុនសវនាការ ដើម្បីឲ្យគាត់ដឹងច្បាស់លាស់អំពីចំនួន និងវិសាលភាពនៃបទល្មើស ដែលត្រូវយកមកពិចារណា ងាយស្រួលរៀបចំមធ្យោបាយការពារខ្លួនទាន់ពេលវេលា ដោយផ្តោតតែលើបទល្មើសត្រូវបានចោទតែប៉ុណ្ណោះ។

**ខ្លឹមសារច្បាប់ដកស្រង់៖** មាត្រា១៥ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ

១.គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធភាពពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឲ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឲ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។

២.គ្មានបញ្ញត្តិណាមួយក្នុមាត្រានេះ ប្រឆាំងនឹងការជនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្តក្នុងខណៈពេលដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ។

## ក្រមនីតិវិធីព្រហ្មទណ្ឌ

មាត្រា៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់)

បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមមិនអាចផុតអាជ្ញាយុកាលបានទេ ។

មាត្រា១០ (អាជ្ញាយុកាលនៃបទល្មើស)

លើកលែងតែបទប្បញ្ញត្តិនៃ មាត្រា៩(ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់) នៃក្រមនេះ ចេញថិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺ ៖

- ១៥ (ដប់ប្រាំ) ឆ្នាំចំពោះបទឧក្រិដ្ឋ, - ៥ (ប្រាំ) ឆ្នាំចំពោះបទមជ្ឈិម និង ១ (មួយ) ឆ្នាំចំពោះបទលហុ

មាត្រា៣ (គោលការណ៍នីត្យានុកូលភាព)

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះទើបអាចត្រូវប្រកាសបាន ។